Disability Rights California

*បណ្ដាញការពារ និង គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា* (California)

អាស័យដ្ឋានគេហទំព័រ: www.disabilityrightsca.org

ទូរស័ព្ទឥតគិតថ្លៃ: (800) 776-5746

TTY: (800) 719-5798

---

**#5: អត្ថន័យសំខាន់ៗស្ដីពីការកាត់ខ្ទង់ថវិកានៃរដ្ឋ (Fact Sheet) សម្រាប់កម្មវិធីផ្ដល់អត្ថប្រយោជន៍នានា – ថ្ងៃទី13 ខែសីហា ឆ្នាំ2009**

**កម្មវិធីជំនួយរ៉ាប់រងលើសេវាកម្មតាមផ្ទះ (IHSS): សកម្មភាពផ្ដិតក្រយៅដៃ និង ប្រឆាំងការក្លែងបន្លំ (FAFA)**

កម្មវិធី IHSS ផ្ដល់សេវាកម្មនានាឲ្យ[1] ដល់មនុស្សដែលមានអាយុលើសពី65ឆ្នាំ ពិការភ្នែក និង ពិការភាពដែលមិនមានលទ្ធភាពរបស់នៅដោយសុវត្ថិភាពនៅផ្ទះរបស់ខ្លួនបាន។[2]

---

[1] កម្មវិធី IHSS មានជាអាទិ៍: សេវាគាំហែទាំផ្ទាល់មិនមែនផ្នែកពេទ្យ សេវាជំនួយផ្នែកពេទ្យ សេវាជំនួយបញ្ហាគ្រួសារ ទំនាក់ទំនងសេវា សេវាដឹកជញ្ជូន សេវាត្រួតពិនិត្យចាត់ចែងការពារសុវត្ថិភាព សេវាសម្អាតធំៗ សេវាសម្អាតបញ្ហាតាមទីធ្លា និង សេវាបង្ហាត់បង្ហាញ។ សូមមើល http://www.disabilityrightsca.org/pubs/547001Index.htm សម្រាប់ព័ត៌មានពិស្តារបន្ថែមទៀត។

## តើហេតុមកទល់ពេលនេះ ច្បាប់មានការប្រែប្រួលយ៉ាងដូចម្តេច?

ចាប់មានប្រសិទ្ធភាពនៅកាលបរិច្ឆេទនានានៅឆ្នាំ2010 និង 2011 ផ្នាក់តំបន់នានា នឹងចាំបាច់ត្រូវប្រកាន់យកចំណាត់ការណ៍ពិតប្រាកដដែលមានគោលដៅការពារការក្លែងបន្លំ ហើយធានាឲ្យបានថា មានតែអ្នកដែលមានសិទ្ធិទទួលសេវា IHSS ប៉ុណ្ណោះដែលទទួលសេវានេះបាន ហើយមានតែសេវាទាំងឡាយណាដែលពួកគេមានសិទ្ធិទទួលតែប៉ុណ្ណោះ។ បម្រែបម្រួលនេះ បង្ហាញឲ្យឃើញច្បាស់អំពីសេចក្តីជូនដំណឹងបន្ថែមចំពោះលក្ខខ័ណ្ឌសម្រាប់អ្នកផ្តល់អ្នកសេវាកម្មនានា ការផ្តិតក្រយៅដៃ ការពិនិត្យលើប្រវត្តិបទឧក្រិដ្ឋ និង ការចុះសួរនាំដល់ផ្ទះ។

## សេចក្តីជូនដំណឹងដល់ក្រុមអ្នកផ្តល់សេវាកម្ម

ក្រុមអ្នកផ្តល់សេវា IHSS នឹងទទួលបាននូវបញ្ជីមួយដែលបញ្ជាក់អំពីការយល់ព្រមលើកាតព្វកិច្ចដែលគេនឹងអនុវត្តចំពោះអ្នកទទួលសេវា IHSS ម្នាក់ៗក្រោម “ការថែទាំព្យាបាល” របស់គ្រូពេទ្យ និង បំពេញបញ្ជីកាតព្វកិច្ចសេវាទ្រទ្រង់ដែលមានក្នុងកម្មវិធី IHSS។ លក្ខខ័ណ្ឌនេះ នឹងត្រូវគេអនុវត្តមិនឲ្យហួសពីថ្ងៃទី1 ខែធ្នូ ឆ្នាំ2011 ទេ។

## ការត្រួតពិនិត្យបញ្ហាស្នាមម្រាមដៃ និង ប្រវត្តិបទឧក្រិដ្ឋសម្រាប់ក្រុមអ្នកផ្តល់សេវា

រាល់អ្នកផ្តល់សេវាទាំងអស់ នឹងចាំបាច់ត្រូវឆ្លងកាត់យន្តការត្រួតពិនិត្យប្រវត្តិបទឧក្រិដ្ឋ ដោយរួមមានទាំងស្នាមម្រាមដៃផង។

---

[2] ក្រមសុខមាលភាព និង ស្ថាប័ន: §12300

## ស្នាមម្រាមដៃនៅលើតារាងម៉ោងការងារ

ចាប់ពីថ្ងៃទី1 ខែមេសា ឆ្នាំ2010 តទៅ ស្នាមម្រាមដៃនឹងត្រូវគេទទួលយកបានពីបេក្ខជនសម្រាប់បម្រើ និង អ្នកទទួលសេវា IHSS ទាំងអស់ តាមរយៈថ្នាក់តំបន់នៅឯពេលនៃការវាយតម្លៃដំបូង ឬ វាយតម្លៃឡើងវិញ។ បុគ្គលដែលជាអានីតិជន ឬ ដែលមានពិការភាពរាងកាយដែលត្រូវផ្តល់ស្នាមម្រាមដៃដោយសារការកាត់អវៈយវៈ ឬ កម្រិតរូបកាយផ្សេងទៀតទទួលបានការលើកលែងចេញពីលក្ខខ័ណ្ឌណាមួយដើម្បីផ្តល់នូវស្នាមម្រាមដៃ។ ចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2011 ទាំងអ្នកផ្តល់ និង ទទួលសេវា នឹងចាំបាច់ត្រូវផ្តល់ស្នាមមេដៃនៅលើតារាងម៉ោងការងារដែលដាក់សុំទៅថ្នាក់តំបន់។

## ការផ្លាស់ប្តូរបន្ថែមលើតារាងម៉ោងការងារ

ច្បាប់ថ្មី បង្កើតឲ្យមាននូវទោសព្រហ្មទណ្ឌមួយសម្រាប់ការក្លែងបន្លំលើតារាងម៉ោងការងារ។ លើសពីនេះទៀតនោះ វាក៏ចាំបាច់ផងដែរឲ្យអ្នកផ្តល់សេវាចុះហត្ថលេខាទទួលស្គាល់សេវាសម្រាប់ទទួលដែលមានសិទ្ធិពិតប្រាកដ។ ទីបំផុតវាចាំបាច់នៅក្នុងការពិនិត្យផ្ទៀងផ្ទាត់មើលលើបុគ្គលចំពោះបញ្ហាឯកសារផ្តល់ការងារឲ្យអ្នកផ្តល់សេវាតាមរយៈបុគ្គលិកថ្នាក់តំបន់។

## ការឆ្មក់ចុះពិនិត្យផ្ទាល់

បុគ្គលិកកិច្ចការសង្គមថ្នាក់តំបន់ នឹងចាំបាច់ត្រូវចុះអនុវត្តន៍ការឆ្មក់ត្រួតពិនិត្យដល់គេហដ្ឋានចំពោះករណីមានហានិភ័យខ្ពស់សម្រាប់សេវា IHSS។

## ការលើកកម្ពស់លើការផ្លាស់ប្តូរសម្រាប់ការអង្កេតរក និង ការពារការក្លែងបន្លំ

ច្បាប់ថ្មី ផ្តល់ថវិកា10លានដុល្លារបន្ថែមទៀតសម្រាប់ការស៊ើបអង្កេត និង ប្រឆាំងការក្លែងបន្លំនៅតាមមូលដ្ឋាន។ វាផ្តល់នូវអំណាចបន្ថែមទៀតដល់ក្រសួងតំហែទាំសុខភាព និង កិច្ចការសង្គមប្រចាំរដ្ឋកាលីហ្វញ៉ាសម្រាប់សកម្មភាពប្រឆាំងការក្លែងបន្លំ។ ច្បាប់ថ្មីនេះ ក៏ចាំបាច់ផងដែរឲ្យថ្នាក់តំបន់នានាបណ្តុះបណ្តាលបុគ្គលិកនៅក្នុងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតលើបញ្ហាប្រឆាំងការក្លែងបន្លំ។ លើសពីនេះ ថ្នាក់តំបន់ចាំបាច់ត្រូវផ្សព្វផ្សាយការកំណត់គោលដៅផ្ញើសំបុត្រតាមពេលវេលាជាក់លាក់។ អ្នកផ្តល់សេវា នឹងត្រូវគេកម្រិតលើបញ្ហាសមត្ថភាពដើម្បីទទួលបានមូលប្បទានប័ត្រតាមប្រអប់សំបុត្រនៅឯការិយាល័យប្រៃសណីយ។

## តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច?

ប្រសិនបើអ្នក ជឿជាក់ថា ការផ្លាស់ប្តូរទាំងនេះនៅក្នុងច្បាប់ កំពុងត្រូវបានគេអនុវត្តមិនត្រឹមត្រូវចំពោះអ្នក ឬ ប្រសិនបើអ្នកជឿជាក់ថា ពួកគេខកខានមិនបានអនុវត្តតាមឥរិយាបថមិនរើសអើងនោះ អ្នកអាចដាក់ពាក្យប្តឹងសុំឲ្យមានសវនាការមួយដូចខាងក្រោម នូវសេចក្តីណែនាំនៅផ្នែកខាងក្រោយនៃសេចក្តីជូនដំណឹងរបស់អ្នកដើម្បីចាត់ការ។ អ្នក ក៏អាចដាក់ពាក្យប្តឹងប្រឆាំងការរើសអើងផងដែរ (តាមមើលសេចក្តីណែនាំតាមរយៈតំណភ្ជាប់នេះ http://www.dss.cahwnet.gov/cdssweb/entres/forms/English/pub13ada.pdf)។

## តើសិទ្ធិជនពិការនៅរដ្ឋកាលីហ្វ័រញ៉ា ប្រឆាំងទៅនឹងការប្រែប្រួលទាំងនេះដែរឬទេ?

ពិតមែនហើយ... សិទ្ធិនៃជនពិការនៅរដ្ឋកាលីហ្វ័រញ៉ា បានប្រឆាំងទៅនឹងបម្រែបម្រួលថ្មីនៃច្បាប់ទាំងនេះ។ យើង ប្រឆាំងទៅនឹងវិសោធនកម្មច្បាប់ទាំងនេះ សម្រាប់ហេតុផលដូចខាងក្រោម:

- កំណែច្បាប់ទាំងនេះ មានលក្ខណៈមិនត្រឹមត្រូវចំពោះអ្នកទទួល និង អ្នកផ្ដល់សេវា IHSS។ វាបន្ថែមនូវបន្ទុកជាច្រើនលើអ្នកទទួល និង អ្នកផ្ដល់សេវាដោយមិនមានផ្ដល់នូវអត្ថប្រយោជន៍ដ៏សំខាន់ណាមួយដល់រដ្ឋ។ និតិវិធីថ្មីៗត្រូវចំណាយខ្ពស់ ហើយស៊ីពេល និង ធ្វើឲ្យកាន់តែពិបាលច្រើនឡើងជាងសព្វដងសម្រាប់អ្នកទទួលស្វែងរកអ្នកផ្ដល់សេវាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
- របាយការណ៍នានាស្ដីពីការក្លែងបន្លំសេវា នៃ IHSS ត្រូវបានគេបំប៉ោងហួសហេតុ ដែលដូច្នេះ កំណែនានានដែលនឹងត្រូវគេអនុវត្តមិនមានមូលដ្ឋានពិតប្រាកដលើការលើកហេតុផលបន្ទរនោះទេ នៅក្នុងកិច្ចបន្ថែមទៅនឹងការដាក់ឲ្យមាននូវបន្ទុកចំណាយរដ្ឋបាលសម្រាប់តាមថ្នាក់តំបន់នោះ។
- កំណែច្បាប់ទាំងនេះ នឹងនាំឲ្យមានការចំណាយខ្ពស់ ហើយពិបាកអនុវត្តក្នុងពេលមួយដែលកំពុងកាត់បន្ថែមកម្មវិធីបណ្ដាញសុវត្ថិភាពដែលចាំបាច់។
- កំណែច្បាប់ទាំងនេះ នឹងមិនផ្ដល់ជាលទ្ធផលអ្វីនៅក្នុងបញ្ហាសន្សំសំចៃថវិកាទេ ក្រៅតែពីបន្ទុកការិយាធិបតេយ្យដ៏សម្បើមដែលបង្ខំឲ្យមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវា IHSS ឈប់ទទួលសេវានានានដែលជាតម្រូវការចាំបាច់របស់ខ្លួន។